ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការបញ្ជូនវត្ថុបុរាណខ្មែរដែលបានបាត់បង់ ត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមជម្រាបជូនព័ត៌មានដល់សាធារណជនមេត្តាជ្រាបថា បន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង គ្រួសារលោក ឌូក្លាស ឡាចហ្វត (Douglas Latchford) ស្តីពីការបញ្ជូនត្រឡប់មកវិញនៃសម្បត្តិវប្បធម៌ខ្មែរ ដូចដែលក្រសួងបានចេញសេចក្តីជូនព័ត៌មានកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ក្នុងនោះមានវត្ថុបុរាណខ្មែរចំនួនជាង ១០០រូប សាងពីថ្ម និងសំរឹទ្ធ នឹងត្រូវបញ្ជូនត្រឡប់មកកម្ពុជាវិញជាបន្តបន្ទាប់។

ក្នុងដំណាក់កាលដំបូងនេះ វត្ថុបុរាណខ្មែរដែលជារតនៈវត្ថុដ៏ល្អឯកចំនួន ៥រូប ក្នុងនោះមានបដិមាថ្មព្រះសិវស្កន្ទ (ព្រះឥសូរនិងព្រះស្កន្ទ) មកពីប្រាសាទកោះកេរ, បដិមាថ្មព្រះអឌ្ឍនារីស្វរៈ (ព្រះឥសូរនិងនាងឧមា) និងកន្សៀទូកសំរឹទ្ធ នឹងត្រូវបញ្ជូនពីប្រទេសអង់គ្លេសមកដល់មាតុភូមិកម្ពុជា នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។ រូបចម្លាក់ទាំង៥រូបនេះ នឹងយកទៅរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ ដើម្បីឱ្យក្រុមជំនាញធ្វើការពិនិត្យវាយតម្លៃ សំអាត ជួសជុល និងដំឡើងជើងទម្រចាំបាច់នានា សម្រាប់ត្រៀមរៀបចំពិធីប្រគល់-ទទួលជាផ្លូវការ នៅពេលវេលាណាមួយសមស្រប តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

# បញ្ជីរូប

| ល.រ | ពិពណ៌នា | រូបថត |
|---|---|---|
| ១ | **សិវស្កន្ទ** (ព្រះឥសូរ និងព្រះស្កន្ទ)<br>ប្រាសាទក្រចាប់, កោះកេរ្តិ៍<br>សម័យអង្គរ, រចនាបថកោះកេរ្តិ៍,<br>ពាក់កណ្តាលទី១នៃស.វទី១០គ.ស.<br>ថ្មភក់<br>ទំហំ៖ ១០៨ x ៦៣ x ៦៥ ស.ម. |  |
| ២ | **កន្ទៀទូក** (ទម្រង់ក្បាលគ្រុឌ)<br>សម័យអង្គរ, រចនាបថបាយ័ន,<br>ចុងស.វ.ទី១២គ.ស.<br>សំរឹទ្ធ<br>ទំហំ៖ ៨១ x ៦៩ x ៣៩ ស.ម. |  |

| | | |
|---|---|---|
| ៣ | **ព្រះអឌ្ឍនារីស្វរៈ**<br>(ព្រះឥសូរ និងនាងឧមា)<br>សម័យអង្គរ, រចនាបថកោះកេរ្តិ៍?,<br>ស.វទី១០គ.ស.<br>ថ្មភក់<br>ទំហំ៖ ៩៤ x ៤១ x ៣៤ ស.ម. |  |
| ៤ | **ព្រះនាងប្រាជ្ញាបារមី**<br>សម័យអង្គរ, រចនាបថបាយ័ន,<br>ចុងស.វ.ទី១២គ.ស.<br>ថ្មភក់<br>ទំហំ៖ ១៣៣ x ៣៤ x ២១ ស.ម. |  |

| | | |
|---|---|---|
| ៥ | **ទេពភេទប្រុស**<br>សម័យអង្គរ, រចនាបថបាភួន,<br>ចុងស.វ.ទី១១គ.ស.<br>សំរឹទ្ធ<br>ទំហំ៖ ៦០ x ៣៨ x ២៩ ស.ម. |  |